# គំនូរក្នុងរូងភ្នំ
# «ពើងជ្រូក» ភ្នំគូលែន

ព្រះរាជាណាចក្រកម្ពុជាមានតំបន់ការពារធម្មជាតិជាច្រើនកន្លែង ដែលត្រូវបានកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣។ ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ជាផ្នែកមួយនៃតំបន់ការពារធម្មជាតិ ដែលមានផ្ទៃដីសរុបចំនួន ៣៧៥០០ ហិចតា និងមានតួនាទីសំខាន់ក្នុងការរក្សាលំនឹងបរិស្ថាននៅតំបន់អង្គរ ដោយសារប្រភពធនធានធម្មជាតិ ព្រៃឈើ ប្រភពទឹក និងជីវចម្រុះ ដែលមាននៅទីនោះ។ ភ្នំគូលែនជាអតីតរាជធានី នៃព្រះបាទជ័យវរ្ម័នទី២ ដែលព្រះអង្គបានធ្វើពិធីទេវរាជនៅលើភ្នំគូលែននោះ។ ម្យ៉ាងទៀតទីតាំងនេះ ក៏ជាកន្លែងប្រវត្តិសាស្ត្រដ៏សំខាន់មួយ ដែលបានរក្សាទុកនៅមរតកវប្បធម៌ជាច្រើនប្រភេទមានដូចជាប្រាសាទបុរាណ ចម្លាក់បាតស្ទឹង ចម្លាក់តាមពើងនានា និងគំនូរតាមពើងថ្មជាច្រើនទីតាំងផងដែរ។

គំនូរត្រូវបានមនុស្សប្រើប្រាស់ជាយូរណាស់មកហើយដូចជានៅរូងភ្នំ Lascaux ប្រទេសបារាំង ដែលមានអាយុកាលចន្លោះ ៣៥០០០ឆ្នាំ-១០០០០ឆ្នាំ[១] ដែលជាសិល្បៈគំនូរក្នុងរូងភ្នំដ៏ចំណាស់។ ចំពោះការសិក្សានេះ ក៏បានបង្ហាញពីសិល្បៈគំនូរក្នុងរូងភ្នំនៅតំបន់អាស៊ីផងដែរ ដូចជានៅប្រទេសថៃដែលបង្ហាញអំពីគំនូរពណ៌ក្រហមក្នុងរូងភ្នំ ដោយគូរជារូបមនុស្សបាញ់ព្រួញ និងសត្វឆ្កែ ដែលគេបានកំណត់អាយុកាលចន្លោះ ៤០០០មក២៥០០ ឆ្នាំមុនបច្ចុប្បន្ន។[២] ក្នុងនោះផងដែរក៏បានបង្ហាញអំពីគំនូរនៅរូងភ្នំក្នុងប្រទេសកម្ពុជា ដែលរកឃើញនៅភ្នំក្រវ៉ាញពើងគំនូរ និងភ្នំគូលែន ពើងគំនូរ និងពើងតាខាប។

ក្នុងអត្ថបទសំណេរមួយដែលសរសេរដោយលោក ហេង ថាន បានលើកមកបង្ហាញអំពីពើងដែលមានគំនូរមួយចំនួននៅតាមចង្កេះភ្នំគូលែន។[៣] លើសពីនេះក្នុងបណ្ដាញពត៌មាន AMS អរិយធម៌ខ្មែរ ក៏ធ្លាប់បានផ្សាយអត្ថបទសំណេរមួយចំនួនទាក់ទងនឹងពើង

---

[១] https://hoopermuseum.earthsci.carleton.ca/2001_human_ka/genushomo18.html

[២] Noel Hidalgo Tan, 2014 Rock Art Research in Southeast Asia: A Synthesis, p76

[៣] ធ្នូ២០០៩-ធ្នូ២០១០, កម្រងអត្ថបទក្នុងបណ្ដាញពត៌មានវប្បធម៌ខ្មែរ, ទំព័រ៩០

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

ដូចជាពើងតាខាប ពើងគំនូរនៅភ្នំគូលែន និងល្អាងគំនូរនៅភ្នំក្រវាញជាដើម។[៨] ដោយឡែកក្នុងអត្ថបទសំណេរនេះ នឹងរៀបរាប់ពីការប្រទះឃើញពើងមួយកន្លែងឈ្មោះថា ពើងជ្រូក ដោយនឹងបង្ហាញពីសារសំខាន់មានអ្វីខ្លះ? ពិសេសនោះ គឺគំនូរផាត់ពណ៌លើជញ្ជាំងពើង។

ពើងជ្រូក ស្ថិតតាមជើងភ្នំគូលែនក្នុងភូមិសាស្ត្រ ភូមិទឹកលិច ឃុំបេងមាលា ស្រុកស្វាយលើ ខេត្តសៀមរាបដែលមានចំនុចនិយាមកា X= 411115 Y= 1491182 (រូបលេខ១)។ ពើងជាទីតាំងដែលមានថ្មរដិបរដុបអាចជ្រក ឬស្នាក់នៅជាបណ្តោះអាសន្នបានកំឡុងពេលចូលព្រៃកាប់អុស និងរកអនុផលព្រៃឈើជាដើម។ តាមរយៈការផ្តល់ពត៌មានពីប្រជាជននៅទីនោះក្នុងកំឡុងឆ្នាំ២០២១នេះ ក្រុមការងារស្រាវជ្រាវរបស់ក្រសួងបរិស្ថានបានចុះដល់ទីតាំងពើងជ្រូកផ្ទាល់ ដែលជាទីតាំងពើងថ្មីមួយទៀត ប្រទះឃើញគំនូរពណ៌នៅលើជញ្ជាំងនៃពើង។ ពើងជ្រូកមានទំហំប្រមាណ២០ម៉ែត្រ (រូបលេខ២) ដោយនៅក្បែរនោះមានពើងជាច្រើន ព្រមទាំងតំបន់នៅម្តុំនោះ ក៏ជាទីតាំងសំខាន់សម្រាប់យកថ្មសាងសង់ប្រាសាទផងដែរ។

ឈ្មោះពើងជ្រូកនេះ គឺជាការហៅតៗគ្នារបស់ប្រជាជនក្នុងតំបន់ ដោយប្រហែលជាការប្រទះឃើញគំនូរពណ៌មានរូបជាជ្រូកពីរក្បាលលើជញ្ជាំងពើង (រូបលេខ៣) ទើបហៅគេថាពើងជ្រូក។ ម្យ៉ាងទៀតនៅលើជញ្ជាំងពើងជ្រូកក៏មានបង្ហាញពីស្លាកស្នាមគំនូរពណ៌ជាច្រើនផ្សេងៗគ្នាដែលពិបាកនឹងធ្វើការកំណត់សម្គាល់ណាស់។ ដោយគំនូរពណ៌នោះមានសណ្ឋានដូចជារូបមនុស្ស មានទំហំប្រមាណ៩០សង់ទីម៉ែត្រ នៅផ្នែកជញ្ជាំងខាងលើនៃពើង កំពស់ប្រមាណ៤ម៉ែត្រពីផ្ទៃដី។ ក្នុងនោះក៏មានបន្សល់ស្នាមពណ៌ដែលប្រតាកផ្នែកខាងលើ និងផ្នែកខាងក្រោម នេះទំនងជាជាជើងមនុស្ស ដែលគូសចេញជាទម្រង់ខ្សែបន្ទាត់ដោយពណ៌ក្រហមស្រាល មានស្នាមឆ្នូតៗរំលេចជារូបរាង (រូបលេខ៤)។ មានគំនូសស្នាមខ្លះៗនៅក្បែរនោះផងដែរ ដែលហាក់ដូចជាមិនរួចរាល់។ នៅផ្នែកខាងក្រោមនៃពើងមានគំូររូបសត្វជ្រូកលាបពណ៌ក្រហមចាស់លើផ្ទៃសត្វជ្រូកទាំងមូល មានទំហំ

[៨] បុរាណវិទ្យា - Page 2 of 6 - AMS Khmer Civilization

ប្រមាណ៥០ស.ម (រូបលេ៥)។ រីឯនៅខាងក្រោមគំនូរសត្វជ្រូកពណ៌ក្រហមចាស់នេះ មានរូបគំនូរសត្វជ្រូកមួយទៀត តែពុំបានលាបពណ៌លើផ្ទៃខ្លួនទាំងមូលទេ ដោយគ្រាន់តែគូរជារូបរាងតែប៉ុណ្ណោះ និងមានទំហំប្រហាក់ប្រហែលគ្នា (រូបលេខ៦)។ ចំពោះ រូបលេខ៧ ជារូបគំនូរមានសណ្ឋានដូចជាមនុស្ស ដែលគេគូរជាលក្ខណៈងាយៗ មានទំហំប្រមាណ ២០សង់ទីម៉ែត្រ។

ដោយឡែករូបគំនូរមួយចំនួនទៀតដែលជួបប្រទះ គឺពិបាកក្នុងការកំណត់ណាស់ ដ្បិតគំនូរនោះគូរជាខ្សែបន្ទាត់ចំនួន៤ខ្សែកាត់គ្នាមានសណ្ឋានដូចសញ្ញាបូក(រូបលេខ៨)។ រូបគំនូរមួយទៀតយើងមិនដឹងថាតើអ្នកគូរមានបំណងចង់គូរអ្វីឱ្យប្រាកដនោះទេ? (រូបលេខ៩) ព្រោះវាជាស្នាកស្នាមឆ្នូតៗដូចឆ្អឹងជំនី តែក៏មិនដឹងច្បាស់ថាជារូបអ្វីដែរ?។ ចំពោះគំនូរ រូបលេខ១០ គេគូរមានរាងមូលដូចពងក្រពើ ៣ជាន់ ក៏យើងមិនដឹងថាជារូបអ្វីដែរ? នៅមានស្នាកស្នាមគំនូរខ្លះៗទៀតដែលពិបាកក្នុងការកំណត់ ដ្បិតគំនូរទាំងនោះមានសភាពរលប់ និងអាយុកាលនៃគំនូរផង។

សរុបមកទីតាំងគំនូរនេះ មិនទាន់មានការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រនៅឡើយទេ។ តាមរយៈបច្ចេកទេសគូរ និងរបៀបគូរ យើងអាចដឹងថាគំនូរនេះពិតជាមានវ័យចំណាស់។ តើគំនូរទាំងនេះមានតាំងពីពេលណាមក? តើវាអាចមានទំនាក់ទំនង និងមនុស្សដែលយកថ្មនៅក្បែរនោះដែរទេ? តំបន់យកថ្មនៅក្បែរនោះត្រូវបានយកក្នុងសម័យអង្គរ ដោយយើងបានជួបប្រទះចម្លាក់ក្នុងរចនាបទអង្គរវត្ត និងរចនាបទបាយ័ន តំបន់នោះដែរ។[៥]

[៥] https://ams.com.kh/khmercivilization/ សូមមើលអត្ថបទពីពើងព្រះពុទ្ធ

អត្ថបទដោយ៖ លឹម វណ្ណចន្ទ




រូបលេខ១៖ ផែនទីទីតាំងពើងជ្រូក



រូបលេខ២៖ ពើងជ្រូក

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ២៣៖ រូបគំនូរលាបពណ៌មានសណ្ឋានជាសត្វជ្រូក



រូបលេខ២៤៖ រូបគំនូរលាបពណ៌មានសណ្ឋានជាសត្វជ្រូក និងរូបលាបពណ៌ផ្សេងៗទៀត

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



*រូបលេខ២៥៖ រូបគំនូរលាបពណ៌មានសណ្ឋានជាសត្វជ្រូក និងរូបលាបពណ៌ផ្សេងៗទៀត*



*រូបលេខ២៦៖ រូបគំនូរលាបពណ៌មានសណ្ឋានជាសត្វជ្រូក*

*អត្ថបទដោយ៖ លឹម វណ្ណចន្ទ*



រូបលេខ៧៖ រូបគំនូរលាបពណ៌ផ្សេងៗ



រូបលេខ៨៖ រូបគំនូរលាបពណ៌មានសណ្ឋានជាសញ្ញាលេខបូក



រូបលេខ៩៖ រូបគំនូរលាបពណ៌ផ្សេងៗ



រូបលេខ១០៖ រូបគំនូរលាបពណ៌ផ្សេងៗ

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ